ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ

សាលាភូមិន្ទរដ្ឋបាល

លេខ...៤៣០....ស.ភ.រ

# សេចក្តីណែនាំ
## ដល់បេក្ខជនក្នុងពេលប្រឡងត្រួតពិនិត្យសមត្ថភាព សម្រាប់វគ្គបណ្តុះបណ្តាលបន្តឆ្នាំ២០១៨ នៃសាលាភូមិន្ទរដ្ឋបាល

បេក្ខជនដែលបានមានបង្កាន់ដៃទទួលពាក្យប្រឡងដែលត្រូវចូលរួមប្រឡងត្រួតពិនិត្យសមត្ថភាពសម្រាប់វគ្គបណ្តុះបណ្តាលបន្តឆ្នាំ២០១៨នៅសាលាភូមិន្ទរដ្ឋបាលត្រូវគោរពអនុវត្តតាមការណែនាំដូចតទៅ៖

- ត្រូវចូលមកសាលាភូមិន្ទរដ្ឋបាលតាមច្រកទ្វារខាងក្រោយ និងយកភ្ជាប់មកជាមួយនូវបង្កាន់ដៃទទួលពាក្យប្រឡង ព្រមទាំងប៊ិចខៀវ សម្រាប់ប្រើប្រាស់ពេលប្រឡង
- ហាមយកជាប់មកជាមួយនូវឯកសារ ទូរស័ព្ទ និងឧបករណ៍អេឡិចត្រូនិកគ្រប់ប្រភេទ។ សាលាមិនទទួលខុសត្រូវរក្សាទុកនូវឯកសារ ទូរស័ព្ទ និងឧបករណ៍អេឡិចត្រូនិចគ្រប់ប្រភេទនេះទេ
- ករណីមកយឺតម៉ោង "តិចជាង ១៥នាទី" ត្រូវសុំការអនុញ្ញាតពីប្រធានអនុគណៈកម្មការកណ្តាលជាមុនទើបអាចចូលប្រឡងបាន និងប្រគល់សន្លឹកកិច្ចការប្រឡងតាមម៉ោងកំណត់។ ការមកយឺតយ៉ាវលើស "១៥នាទី" មិនអនុញ្ញាតឲ្យចូលប្រឡងដាច់ខាត។
- មិនត្រូវចូលបន្ទប់ប្រឡងមុនពេលហៅឈ្មោះ ត្រូវអង្គុយតាមលេខតុដែលបង្ហាញ ត្រូវសរសេរឈ្មោះ និងលេខតុលើក្បាលសន្លឹកកិច្ចការប្រឡងតាមការណែនាំរបស់អនុរក្ស និងប្រគល់សន្លឹកកិច្ចការប្រឡងដល់អនុរក្សវិញ។ ការមិនប្រគល់សន្លឹកកិច្ចការប្រឡងដល់អនុរក្ស ចាត់ទុកជាអវត្តមាន។
- មិនត្រូវសរសេរក្នុងសញ្ញាខ្វែងនៃគ្រប់ទំព័រសន្លឹកកិច្ចការប្រឡង និងមិនត្រូវធ្វើគំនូសសញ្ញាធ្វើឲ្យដឹងអាគតដ្ឋាននៃសន្លឹកកិច្ចការប្រឡងឡើយ
- មិនត្រូវធ្វើសកម្មភាពលួចចម្លងតាមគ្រប់រូបភាព មិនប៉ុនប៉ងលួចចម្លង ឬចែករំលែកព័ត៌មានដល់អ្នកដទៃ។
- បេក្ខជនត្រូវដឹងអំពីសញ្ញាកណ្តឹង៖
    + កណ្តឹងទី១៖ ចូលបន្ទប់ប្រឡងបំពេញក្បាលសន្លឹកកិច្ចការប្រឡង
    + កណ្តឹងទី២៖ ចាប់ផ្តើមធ្វើវិញ្ញាសា
    + កណ្តឹងទី៣៖ រំឭកថានៅសល់ ១៥នាទីទៀត ដល់ម៉ោងត្រូវប្រមូលសន្លឹកកិច្ចការប្រឡង
    + កណ្តឹងទី៤៖ ប្រគល់សន្លឹកកិច្ចការប្រឡងឲ្យអនុរក្សជាកំហិត។

បេក្ខជនដែលមិនគោរពប្រតិបត្តិតាមការណែនាំខាងលើនេះ ឬគំរាមកំហែង ឬធ្វើឲ្យប៉ះពាល់ដល់កិត្តិយស បុរណភាពរូបកាយមន្ត្រីមានសមត្ថកិច្ចទាំងក្នុងបន្ទប់ប្រឡង និងក្រៅបន្ទប់ប្រឡង នឹងត្រូវបញ្ឈប់មិនឲ្យប្រឡងជាបន្ទាន់ក្នុងសម័យប្រឡងដែលកំពុងប្រព្រឹត្តនេះ និងព្រមទាំងទទួលខុសត្រូវតាមវិធានច្បាប់ជាធរមាន ព្រមទាំងស្ថិតក្នុងវិធានវិន័យរបស់សាលាភូមិន្ទរដ្ឋបាល។

គណៈមេប្រយោគមានជំនឿយ៉ាងមុតមាំចំពោះស្មារតីទទួលខុសត្រូវ និងចូលរួមថែរក្សាឲ្យបាននូវភាពរលូននៃដំណើរការប្រឡងរបស់បេក្ខជនទាំងអស់។

ថ្ងៃអង្គារ ១៥កើត ខែ ពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែឧសភា ឆ្នាំ២០១៨

ជ.គណៈមេប្រយោគ

ប្រធាន

ពេជ្រ ម៉ុនធិន

អាសយដ្ឋាន : អគារលេខ ១៧ វិថីឧកញ៉ាញឹកជូឡុង (៩៦ រាជធានីភ្នំពេញ , ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ : 023 62 22 266

អ៊ីម៉ែល : era.rsa@gmail.com គេហទំព័រ : www.era.cambodia.gov.kh